# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តឧត្តរមានជ័យ**

លេខ: ១៧៥ សជណ.ខ្ជ

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១២

យោង : លិខិតលេខ ៨៦៤ អពដ. ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ របស់អគ្គនាយកដ្ឋានពន្ធដារ ស្ដីពីការគ្រប់គ្រង និង ការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១២ ។

**អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ** សូមជូនដំណឹងដល់ ឯកឧត្ដម អ្នកឧកញ៉ា លោកជំទាវ លោក-លោកស្រី ទាំងអស់មេត្តាជ្រាបថា ការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១១ ត្រូវប្រមូលចាប់ពីថ្ងៃជូនដំណឹងនេះត **ទៅរហូតដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១២** ។ ឯការត្រួតពិនិត្យលើការបង់ពន្ធនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែ **តុលា ឆ្នាំ២០១២** តទៅ ។

ម្ចាស់អចលនទ្រព្យទាំងអស់ ទោះត្រូវជាប់ឬមិនត្រូវជាប់ពន្ធលើអចលនទ្រព្យក្ដី ត្រូវបំ ពេញព័ត៌មានអចលនទ្រព្យ ក្នុងទម្រង់លិខិត ដែលផ្ដល់ដោយសាលាសង្កាត់ ឬ មន្ត្រីពន្ធដារហើយត្រូវប្រគល់វិញក្នុងរយៈពេលយ៉ាងយូរ ១០ ថ្ងៃ នៃថ្ងៃ ធ្វើការបន្ទាប់ពីបានទទួលទម្រង់លិខិត ព័ត៌មានអចលនទ្រព្យនោះ ។

អចលនទ្រព្យដែលមិនស្ថិតក្នុងករណីលើកលែង និង មានតម្លៃលើសពី ១០០ លានរៀល ត្រូវចុះបញ្ជីដាក់លិខិតប្រកាស និង បង់ពន្ធនៅសាខាពន្ធដារខេត្ត ដែលអចលនទ្រព្យស្ថិតនៅ ។

ការចុះបញ្ជីត្រូវភ្ជាប់មកជាមួយនូវឯកសារថតចម្លងដូចជា : អត្តសញ្ញាណបណ្ណ ឬ សំបុត្របញ្ជាក់កំណើត ឬ លិខិតឆ្លងដែន(ជនបរទេស), សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ លិខិតបញ្ជាក់ទីលំនៅ, បណ្ណសម្គាល់សិទ្ធិ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់ ឬ វិញ្ញាបនបត្រសម្គាល់ម្ចាស់អលចនវត្ថុដែលចេញដោយរដ្ឋបាលសូរិយោដី ឬ ឯកសារពាក់ព័ន្ធ នឹងការកាន់កាប់អចលនទ្រព្យ ដែលបញ្ជាក់ដោយឃុំ សង្កាត់ឡើងទៅ ។

អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្ដម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ពិតជាមានការភ្ញាក់រលឹកខ្ពស់ ហើយអញ្ជើញទៅ បំពេញកាតព្វកិច្ចបង់ពន្ធនេះ អោយបានរួសរាន់ទាន់ពេលវេលាជាពុំខានឡើយ ។

ឧត្តរមានជ័យ,ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១២

**អភិបាលខេត្ត**

**ប៊ិច_សុខិន**

<u>ចម្លងជូន</u> :

-ក្រសួងមហាផ្ទៃ
-អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ឯកឧត្ដមប្រធានក្រុមប្រឹក្សាខេត្ត
( ដើម្បីជូនជ្រាប )
-សាខាពន្ធដារខេត្ត
-ក្រុមជំនួយការអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ
-ក្រុមការងារអចលនទ្រព្យនៅសង្កាត់ទាំង៥
(ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ